# ក្រុមហ៊ុនព្រលានយន្តហោះថ្មីខេត្តកណ្ដាលប្រើគ្រឿងចក្រកាយដីលុបផ្ទះពលរដ្ឋរស់នៅលើទំនប់៩៤ ដើម្បីបង្ខំឱ្យចាកចេញ



*ផ្ទះពលរដ្ឋនៅលើទំនប់៩៤ ត្រូវបានគ្រឿងចក្រកាយដីលុប ដើម្បីសង់ព្រលានយន្តហោះថ្មី ស្ថិតនៅភូមិអំពៅព្រៃ ឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។ (រូបភាព៖ ទូក ពិសិដ្ឋ)*

គ្រឿងចក្រជាច្រើនគ្រឿងរបស់ក្រុមហ៊ុនសង់ព្រលានយន្តហោះថ្មី បានចាក់ដីលុបផ្ទះរបស់អ្នកភូមិដែលរស់នៅលើទំនប់៩៤ ក្នុងខេត្តកណ្ដាល ដើម្បីបង្ខំឱ្យពួកគេចាកចេញពីតាំងនេះទាំងមិនទាន់ទទួលដំណោះស្រាយ ខណៈសង្គមស៊ីវិលចាត់ទុកថា សកម្មភាពនេះជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។

ពលរដ្ឋម្នាក់គឺ លោក **ស៊ីម ផាន់នី** អាយុ ៥៥ឆ្នាំ រស់នៅលើទំនប់៩៤ ក្នុងស្រុកកណ្ដាលស្ទឹង បានប្រាប់ Newsroom Cambodia ថា មុននឹងមានការចាក់ដីលុបផ្ទះប្រជាពលរដ្ឋនេះ ក្រុមហ៊ុនព្រលានយន្តហោះបានឱ្យក្រុមសន្តិសុខដើរបាញ់លេខផ្ទះដើម្បីឱ្យពលរដ្ឋចាកចេញម្ដងរួចមកហើយ។ លោកថា ក្រោយមកប្រជាពលរដ្ឋបាននាំគ្នាតវ៉ានៅមុខសាលាខេត្តកណ្ដាល ដើម្បីរកកិច្ចអន្តរាគមន៍ពីអាជ្ញាធរថ្នាក់ខេត្ត ប៉ុន្តែគ្មានដំណោះស្រាយនោះទេ។

លោកឱ្យដឹងទៀតថា ប្រជាពលរដ្ឋដែលកំពុងរស់នៅលើទំនប់៩៤ សរុបចំនួន ៥៧៩គ្រួសារ គ្រោងដាក់ញត្តិនៅក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធផ្សេងទៀតដើម្បីរកដំណោះស្រាយ ប៉ុន្តែនៅថ្ងៃទី៨ ខែមិថុនា បែរជាមានគ្រឿងចក្រជាច្រើនគ្រឿងមកចាក់ដីលុបផ្ទះប្រជាពលរដ្ឋកំពុងរស់នៅតែម្ដង។ លោកបន្ថែមថា ភាគីក្រុមហ៊ុនបានបញ្ជាឱ្យក្រុមសន្តិសុខជាច្រើននាក់មកទប់ស្កាត់ពលរដ្ឋដែលឃាត់គ្រឿង

ចក្រមិនឱ្យចាក់ដី ក៏មានការប៉ះទង្គិចគ្នា ប៉ុន្តែមិនបង្កឱ្យមានអ្នករងរបួសនោះទេ។

យ៉ាងណា លោក **ផាន់នី** ចាត់ទុកថា ការកាយដីលុបផ្ទះរបស់លោកនេះ គឺជាចេតនាបង្ខំឱ្យពលរដ្ឋចាកចេញទាំងបង្ខំ ដោយមិនទាន់ទូទាត់សំណងសមរម្យណាមួយនៅឡើយទេ។

លោកថា៖ *«គេចាក់ដីហ្នឹងគឺបង្ខំពួកខ្ញុំឱ្យចាកចេញហ្មង។ ពេលពួកខ្ញុំទៅឃាត់គ្រឿងចក្របែរជាមានខាងក្រុមសន្តិសុខព្រលានមករាំងពួកខ្ញុំ។ ពួកខ្ញុំដាច់ខាតមិនព្រមចាកចេញឡើយ ព្រោះពួកខ្ញុំបានរស់នៅយូរហើយ។ អ្នកណាចង់ចាកចេញពីកន្លែងកំណើត។ ខ្ញុំឈឺចិត្តណាស់អូន!»*។

បើតាម លោក **ស៊ីម ផាន់នី** បានឱ្យដឹងបន្តថា ក្រុមហ៊ុនបានធ្វើសកម្មភាពចាក់ដីនេះ ចាប់តាំងពីដើមខែមេសា ឆ្នាំ២០២៣ មកម្លេះ ប៉ុន្តែមិនទាន់ប៉ះដល់ផ្ទះរបស់ពួកគាត់នោះទេ ទើបតែក្នុងថ្ងៃទី៨ ខែមិថុនា ស្រាប់តែគ្រឿងចក្រទាំងនេះ ចាប់ផ្តើមចាក់ដីលុបផ្ទះអ្នកភូមិតែម្តង។

ចំណែក ពលរដ្ឋម្នាក់ទៀត អ្នកស្រី **ដោ៉ គឹម** វ័យ៣៣ឆ្នាំ រស់នៅភូមិអំពៅព្រៃ ក្នុងឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ដែលមានផ្ទះត្រូវខាងព្រលានយន្តហោះចាក់ដីលុបដែរនោះ បាននិយាយថា ការចាក់លុបនេះធ្វើឱ្យពលរដ្ឋទាំងអស់មានការភិតភ័យជាខ្លាំង ព្រោះមិនមានការ

ជូនដំណឹងជាមុន។ អ្នកស្រីតាំងចិត្តថា សម្រាប់ខ្លួនអ្នកស្រី និងពលរដ្ឋទាំងអស់មិនព្រមចាកចេញនោះទេ បើគ្មានដំណោះស្រាយសមស្រប ដែលអ្នកស្រីអាចទទួលយកបាន។ អ្នកស្រីបានចាត់ទុកថា វាជាការគំរាមកំហែងធ្ងន់ធ្ងរពីក្រុមហ៊ុនព្រលានយន្តហោះ និងជាការបំភិតបំភ័យមនុស្សទាំងស្រុង ដែលជាចេតនាបង្ខំពលរដ្ឋឱ្យចាកចេញទាំងគ្មានដំណោះស្រាយ។

អ្នកស្រីថា៖ *«ខ្ញុំភ័យណាស់គេមកដល់ចាក់ដីលុបយកហ្មង។ ខ្ញុំដេកអត់លក់ទេអូន មិនដឹងថាគេគិតម៉េចបានជាគេមកធ្វើចឹង។ ពួកខ្ញុំតវ៉ារហូតដល់ខេត្តទៀត ប៉ុន្តែគ្មានខាងណាអើពើទេ។មិនមែនទើបមករស់នៅណា ម្នាក់ៗយូរឆ្នាំហើយ។ ខ្ញុំពិបាកចិត្តណាស់ មិនដឹងទៅរស់នៅកន្លែងណា កន្លែងណីទេ»*។

កាលពីពេលថ្មីៗនេះ ពលរដ្ឋ ៤៧៤ គ្រួសារ រស់នៅលើទំនប់៩៤ មកពីឃុំកណ្ដោកក្នុងស្រុកកណ្ដាលស្ទឹង និងសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ បាននាំគ្នាតវ៉ានៅមុខសាលាខេត្តកណ្ដាល ស្នើសុំជួបអភិបាលខេត្តកណ្ដាល លោក **គង់ សោភ័ណ្ឌ** ដើម្បីបំភ្លឺពាក់ព័ន្ធនឹងការបាញ់ថ្នាំផ្ទះពលរដ្ឋ ប៉ុន្តែមិនបានជួបដូចការគ្រោងទុក។ ក្រោយមក អ្នកភូមិបានស្នើឱ្យអាជ្ញាធរចេញបណ្ណកម្មសិទ្ធិស្របច្បាប់ និងឱ្យមានការអភិវឌ្ឍនៅនឹងកន្លែង រហូតមកដល់ពេលនេះ ពលរដ្ឋអះអាងថា គ្មានការឆ្លើយតបណាមួយពីរដ្ឋបាលខេត្តកណ្ដាលនៅឡើយ។

ជុំវិញករណីនេះ លោក **ហេង ចាន់** មេឃុំកណ្តោក បានទទួលស្គាល់ថាពិតជាមានការចាក់ដីពិតមែន ប៉ុន្តែលោកបដិសេធពន្យល់បន្ថែមពីករណីនេះ។

លោកថា៖ *«ពូអត់ដឹងរឿងហ្នឹងផងក្មួយ។ វាជាចំណាត់ការថ្នាក់លើក្មួយ! ពូអត់ដឹងដែរ»*។

ប្រធានផ្នែកដោះស្រាយទំនាស់ដីធ្លីនៃក្រុមហ៊ុនព្រលានយន្តហោះថ្មី លោក **ជីវ កុកសាយ**និយាយថា ដំណោះស្រាយសម្រាប់ពលរដ្ឋនៅលើទំនប់ ៩៤ គឺមានរួចហើយ ប៉ុន្តែលោកថាពួកគាត់មិនព្រមទទួលយក។ យ៉ាងណា លោកមិនបានបញ្ជាក់អំពីដំណោះស្រាយច្បាស់លាស់ណាមួយឡើយជាមួយអ្នកសារព័ត៌មាននោះទេ។

លោកថា៖ *«គេមានតើ [ដំណោះស្រាយ] ណាស់តែពួកគាត់មិនព្រមទទួល ហើយចេះចង់បាននេះ ចង់បាននោះមិនឈប់។ អាហ្នឹងយើងក៏មិនដឹងធ្វើម៉េចដែរ»*។

Newsroom Cambodia មិនអាចសុំការបំភ្លឺបន្ថែមពីអភិបាលខេត្តកណ្តាល លោក **គង់ សោភ័ណ្ឌ** និងលោក **គ្រុយ ម៉ាឡែន** អ្នកនាំពាក្យសាលាខេត្តកណ្តាលជុំវិញចំណាត់ការរបស់រដ្ឋបាលខេត្តបានទេ នៅថ្ងៃទី៩ និងទី១០ ខែមិថុនា ដោយទូរសព្ទចូលជាច្រើនលើកប៉ុន្តែមិនមានអ្នកទទួល។

មន្ត្រីសម្របសម្រួល និងធុរៈកិច្ចនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក **វណ្ណ សុជាត** លើកឡើងថា ការចាក់ដីលុបផ្ទះប្រជាពលរដ្ឋកំពុងរស់នៅនេះ គឺជាការរំលោភទាំងរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងច្បាប់អស្សាមិករណ៍ ដែលចែងថា រាល់ការអភិវឌ្ឍទាំងអស់ត្រូវទូទាត់សំណងឱ្យបានសមរម្យជាមុនសិន។ លោកសង្កេតឃើញថា ភាគីក្រុមហ៊ុនបានប្រើប្រាស់អំណាចរបស់ខ្លួនទាំងបំពានផ្លូវច្បាប់ ដែលជាសកម្មភាពមិនគួរកើតមាននោះទេ។

លោកថា៖ *«ការចាក់ដីលើផ្ទះប្រជាពលរដ្ឋជាការគំរាមកំហែង វាជាការបង្ខំដោយផ្ទាល់តែម្តង។វាជាការរំលោភច្បាប់ហើយ។ រឿងនេះគឺត្រូវអាជ្ញាធរខេត្ត ឬអាជ្ញាធរមូលដ្ឋានត្រូវមានវិធានការ។ វាជាការរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋ វាខុសនឹងនីតិវិធីនៃការដោះស្រាយទំនាស់ដីធ្លីទៀត»*។

ច្បាប់អស្សាមិករណ៍ មាត្រា២២ ចែងថា៖ *«ប្រាក់សំណងដែលត្រូវផ្តល់ទៅឱ្យម្ចាស់អចលនវត្ថុនិង /ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសទៅតាមកាលបរិច្ឆេទ នៃការចេញសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍»*។

យ៉ាណាក្តី មិនមែនមានតែប្រជាពលរដ្ឋរស់នៅលើទំនប់៩៤ នោះទេ ដែលត្រូវរងការបណ្តេញចេញ។ កន្លងមកក៏មានប្រជាពលរដ្ឋរាប់រយគ្រួសារដែលរស់នៅស្រុកបាទី ខេត្តតាកែវ និងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានរងនូវផលប៉ះពាល់ដីជាច្រើនហិកតា និងផ្ទះសំបែងចំនួនរាប់សិបខ្នងពីគម្រោងសាងសង់ព្រលានយន្តហោះអន្តរជាតិតេជោក្នុងតាខ្មៅនេះដែរ។ប្រជាពលរដ្ឋទាំងនោះតែងតែនាំគ្នាតវ៉ារហូតមានការប៉ះទង្គិចគ្នារវាងអាជ្ញាធរ និងពលរដ្ឋ និងមានការចាប់ខ្លួនដាក់ពន្ធនាគារថែមទៀតផង។

ប្រធានគម្រោងសិទ្ធិលំនៅឋាន និងស្រាវជ្រាវនៃអង្គការសមាគមធាងត្នោត លោក **ស៊ាង មួយឡៃ** បានលើកឡើងថា មុននឹងអាជ្ញាធរធ្វើសកម្មភាពចាក់ដីលុបផ្ទះអ្នកភូមិ គឺត្រូវពន្យល់ និងផ្សព្វផ្សាយដល់ពួកគាត់សិនដើម្បីឱ្យមានកិច្ចសហការល្អប្រសើរ រវាងពលរដ្ឋនិងអាជ្ញាធរ។ លោកបន្តថា ពលរដ្ឋមានសិទ្ធិរស់នៅដោយស្របច្បាប់លើដីកំណើតរបស់ខ្លួន និងទទួលបាននូវកិច្ចគាំពារពីរដ្ឋបន្ថែមទៀត។

លោកថា៖ «*កាលណាគ្មានសំណង ហើយមកចាក់ដីនេះគឺចាត់ទុកថាជាការបណ្តេញចេញបង្ខំហើយ។ វាខុសគោលការណ៍សិទ្ធិដែលកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ ក៏ដូចជាគោលការណ៍ទាក់ទងនឹងការបណ្តេញចេញដែលគេបានការពារ និងបានបញ្ជាក់ច្បាស់ៗមុន*

*នឹងការដោះដូរទីតាំងថ្មីត្រូវធ្វើម៉េចកុំឱ្យវាត្រូវទម្រង់បណ្ដោញចេញដោយបង្ខំ»។*

ក្រុមហ៊ុនសាងសង់ព្រលានយន្តហោះកម្ពុជា (CAIC) បានបង្កើតឡើងរួមគ្នាដោយ ក្រុមហ៊ុន OCIC និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា ក្នុងឆ្នាំ២០១៨ ក្រោមការណែនាំរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ដើម្បីសាងសង់ព្រលានយន្តភ្នំពេញថ្មី ដែលស្ថិតនៅចម្ងាយ២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ លើផ្ទៃដីសរុប២៦០០ហិកតាដោយគម្រោងសាងសង់មាន៣ដំណាក់កាល។

ដំណាក់កាលទី១នេះ ត្រូវបានក្រុមហ៊ុនអះអាងថា គ្រោងនឹងចំណាយថវិកា១ ៥០០លានដុល្លារអាមេរិក ដែលមិនទាន់គិតបញ្ចូលតម្លៃដីនៅឡើយនោះទេ ដែលអាចនឹងទទួលបានភ្ញៀវទេសចរ ១៣លាននាក់ក្នុង១ឆ្នាំ ហើយដំណាក់កាលទី២ នឹងបញ្ចប់នៅឆ្នាំ២០៣០ អាចទទួលភ្ញៀវទេសចរ៣០លាននាក់ក្នុង១ឆ្នាំ និងដំណាក់កាលទី៣ នឹងបញ្ចប់នៅឆ្នាំ២០៥០ អាចទទួលភ្ញៀវទេសចរ ៥០លាននាក់ក្នុង១ឆ្នាំ៕